**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សារជូនពរ**

**សូមគោរពជូន**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា**

**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ**

**សម្តេចវិបុលសេនាភក្តី និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសប្រកបដោយនក្ខត្តឫក្ស នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ គ្រិស្តសករាជ ២០១៧នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំ និងភរិយាខ្ញុំ សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់យ៉ាង ជូនចំពោះ **សម្តេចវិបុលសេនាភក្តី** និង**លោកជំទាវ** សូមសម្តេចទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាងសមិទ្ធផលថ្មីៗថែមទៀត ជូនជាតិមាតុភូមិ និងប្រជាពលរដ្ឋ។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រចំពោះ **សម្តេចវិបុលសេនាភក្តី** ដែលកន្លងមកក៏ដូចបច្ចុប្បន្ន **សម្តេច** បានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្តនិងប្រាជ្ញាស្មារតី ដឹកនាំស្ថាប័នព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សម្រេចបានជោគជ័យដ៏ត្រចះត្រចង់ជាបន្តបន្ទាប់ និងបានដើរតួនាទីជាឆ្អឹងខ្នងដ៏រឹងមាំក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ កងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំ និងភរិយាខ្ញុំ សូមលើកហត្ថប្រណម្យបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ ទេវតាឆ្នាំថ្មី និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះអង្គតាមជួយបីបាច់ថែរក្សាប្រោះព្រំសព្ទសាធុការពរជ័យ ជូនចំពោះ **សម្តេចវិបុលសេនាភក្តី** និង**លោកជំទាវ** ព្រមទាំងបុត្រាបុត្រី **ចៅប្រុសចៅស្រី**ជាទីស្រឡាញ់ សូមសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា** និង**លោកជំទាវ** មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh